## កិច្ចសន្យាធានារ៉ាប់រងលើហានិភ័យសម្រាប់អ្នកម៉ៅការសំណង់

ដោយហេតុថា បុគ្គលទទួលការធានារ៉ាប់រងដូចមានឈ្មោះនៅក្នុងឧបសម្ព័ន្ធនេះ បានដាក់ជូនទៅកាន់ក្រុមហ៊ុនដែលមានឈ្មោះខាងលើ (តទៅនេះហៅថា "ក្រុមហ៊ុនធានារ៉ាប់រង") នូវសំណើជាលាយលក្ខណ៍អក្សរតាមរយៈការបំពេញកម្រងសំនួររួមគ្នាជាមួយនឹងសេចក្តីថ្លែងការណ៍ណាមួយផ្សេងទៀត ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរដោយបុគ្គលទទួលការធានារ៉ាប់រងតាមគោលបំណងរបស់កិច្ចសន្យាធានារ៉ាប់រងនេះដែលតទៅត្រូវបានបញ្ចូលនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះ។កិច្ចសន្យាធានារ៉ាប់រងនេះសំដៅចំពោះបុគ្គលទទួលការធានារ៉ាប់រង ដែលបានបង់ឲ្យបុគ្គលធានារ៉ាប់រងនូវបុព្វលាភធានារ៉ាប់រងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ និងយោងទៅតាម ខ ករណីលើកលែង បញ្ញត្តិ លក្ខខណ្ឌដែលមានចែងតទៅនេះ ឬបដិលេខក្រុមហ៊ុនធានារ៉ាប់រងនឹងផ្តល់សំណងជូនបុគ្គលទទួលការធានារ៉ាប់រងក្នុងលក្ខណៈ និងវិសាលភាពដូចមានចែងដូចខាងក្រោម។

### ករណីលើកលែងទូទៅ

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនផ្តល់សំណងដល់បុគ្គលទទួលការធានារ៉ាប់រងឡើយ ចំពោះករណីនៃការបាត់បង់ ខូចខាត ឬការទទួលខុសត្រូវដែលបណ្តាលមកពី ឬកើតឡើង ឬធ្វើឲ្យកាន់តែធ្ងន់ធ្ងរផ្ទាល់ ឬដោយប្រយោលដោយសារៈ

ក) សង្គ្រាម ការឈ្លានពាន ទង្វើរបស់សត្រូវបរទេស ចំណាប់ខ្មាំង (ទោះបីជាសង្គ្រាមនោះត្រូវបានប្រកាស ឬមិនប្រកាសក៏ដោយ) សង្គ្រាមស៊ីវិល ឧទ្ទាមកម្ម ការធ្វើបដិវត្តន៍ ការចលាចល ការបះបោរ កុប្បកម្ម កូដកម្ម ការមិនអនុញ្ញាតឲ្យនិយោជិត ឬកម្មករចូលកន្លែងធ្វើការ ការរំដើបរំជួលស៊ីវិល អំណាចយោធា ឬការដណ្តើមអំណាច ក្រុមមនុស្សព្យាបាទ ឬមនុស្សដែលតំណាងឲ្យ ឬដែលមានទំនាក់ទំនងជាមួយនឹងស្ថាប័ននយោបាយ ការរួមគំនិតក្បត់ ការរឹបអូស ការកេណ្ឌ ការប្តឹងផ្តល់ ឬបំផ្លិចបំផ្លាញ ឬក៏ធ្វើអោយខូចខាតដោយបញ្ជាណាមួយរបស់រដ្ឋាភិបាលដោយស្របច្បាប់ ឬមិនស្របច្បាប់ ឬដោយអាជ្ញាធរសាធារណៈ។

ខ) ប្រតិកម្មនុយក្លេអ៊ែរ ចំហាយដែលភាយចេញពីជាតិនុយក្លេអ៊ែរ ឬការឆ្លងដោយធាតុវិទ្យុសកម្ម។

គ) សកម្មភាពដោយចេតនា ឬការធ្វេសប្រហែសដោយចេតនារបស់បុគ្គលទទួលការធានារ៉ាប់រង ឬតំណាងរបស់ខ្លួន។

ឃ) ការឈប់សកម្មភាពការងារ ទោះទាំងស្រុង ឬដោយផ្នែក។

### បដិលេខចំពោះការលើកលែងភេរវកម្ម

ទោះបីជាមានបទបញ្ញត្តិណាមួយផ្ទុយទៅនឹងការធានារ៉ាប់រងនេះ ឬការឯកភាពណាមួយក៏ដោយ មានការព្រមព្រៀងគ្នាថា ការធានារ៉ាប់រងនេះមិនរួមបញ្ចូលការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬដោយប្រយោល ដែលបណ្តាលមកពី ឬពាក់ព័ន្ធនឹងសកម្មភាពភេរវកម្មណាមួយ ដោយមិនគិតពីបុព្វហេតុ ឬព្រឹត្តិការណ៍ណាមួយផ្សេងទៀតដែលរួមចំណែក ឬជាលទ្ធផលបង្កឲ្យមានការបាត់បង់នោះឡើយ។

សម្រាប់គោលបំណងនៃបដិលេខនេះ សកម្មភាពភេរវកម្មសំដៅលើសកម្មភាពមួយដែលមានជាអាទ៍ដូចជា ការប្រើកម្លាំង ឬអំពើហិង្សា និង/ឬការគំរាមកំហែងប្រើកម្លាំង ឬអំពើហិង្សារបស់បុគ្គលណាមួយ ឬក្រុមហ៊ុនណាមួយរបស់បុគ្គលបើទោះបីជាប្រព្រឹត្តតែម្នាក់ឯង ឬក្នុងនាម ឬពាក់ព័ន្ធនឹងអង្គភាពណាមួយ ឬរដ្ឋាភិបាល សម្រាប់គោលបំណងនយោបាយ និងសាសនា មនោគមវិជ្ជា ឬគោលបំណងស្រដៀងគ្នានេះ ដែលរួមមានចេតនាប្រើឥទ្ធិពលលើរដ្ឋាភិបាលណាមួយ និង/ឬដើម្បីបង្កការភ័យខ្លាចដល់សាធារណជន ឬក្រុមណាមួយនៃសាធារណជននោះ។

បដិលេខនេះ ក៏មិនរួមបញ្ចូលផងដែរនូវការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយអ្វីក៏ដោយ ដែលត្រូវបានបង្កឡើងដោយផ្ទាល់ ឬប្រយោល កើតឡើងមកពី ឬពាក់ព័ន្ធនឹងការចាត់វិធានការណាមួយដើម្បីគ្រប់គ្រង ទប់ស្កាត់បង្ក្រាប ឬទាក់ទងនឹងសកម្មភាពភេរវកម្មតាមវិធីណាមួយ។

ប្រសិនបើក្រុមហ៊ុនចោទប្រកាន់ថា តាមរយៈហេតុផលនៃការលើកលែងនេះ ការបាត់បង់ ការខូចខាត សោហ៊ុយ ឬការចំណាយណាមួយ មិនត្រូវបានធានាដោយកិច្ចសន្យាធានារ៉ាប់រងនេះ បន្ទុកនៃការបញ្ជាក់អ្វីដែលផ្ទុយ ត្រូវធ្លាក់លើបុគ្គលទទួលការធានារ៉ាប់រង។

ក្នុងករណីដែលផ្នែកណាមួយនៃបដ្ឋិលេខនេះ ត្រូវបានរកឃើញថាមិនមានសុពលភាព ឬមិនអាចអនុវត្តបាន ផ្នែកផ្សេងទៀតដែលនៅសល់ នៅតែស្ថិតនៅជាធរមាន និងមានសុពលភាពពេញលេញ។

NMA2921

០៨/១០/២០០១

## ការបញ្ជាក់ពីលក្ខខណ្ឌទាក់ទិននឹងព័ត៌មានវិទ្យា

ការខូចខាតទ្រព្យសម្បត្តិដែលគ្របដណ្តប់ដោយការធានារ៉ាប់រងនេះ សំដៅលើការខូចខាតជារូបវន្ត ចំពោះផ្នែកណាមួយនៃទ្រព្យសម្បត្តិ។

ការខូចខាតជារូបវន្តចំពោះផ្នែកណាមួយនៃទ្រព្យសម្បត្តិមិនត្រូវរួមបញ្ចូលនូវការខូចខាតចំពោះទិន្នន័យ ឬកម្មវិធីសូហ្វវែរ (software) ជាពិសេសការប្រែប្រួលទិន្នន័យ កម្មវិធីសូហ្វវែរ និងកម្មវិធីកុំព្យូទ័រដែលបណ្តាលឲ្យមានការខាតបង់ផលប្រយោជន៍ ដែលត្រូវបានបង្កឡើងដោយការលុបចោល ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃទម្រង់ដើម។

ជាលទ្ធផល ចំនុចខាងក្រោមនេះ ត្រូវបានលើកលែងចេញពីការធានារ៉ាប់រង:

ក. ការបាត់បង់ ឬការខូចខាតទិន្នន័យ ឬកម្មវិធីសូហ្វវែរ ជាពិសេសការប្រែប្រួលទិន្នន័យ កម្មវិធីសូហ្វវែរ និងកម្មវិធីកុំព្យូទ័រដែលបណ្តាលឲ្យ មានការខាតបង់ផលប្រយោជន៍ដែលត្រូវបានបង្កឡើងដោយការលុបចោល ការប្រែប្រួល ឬការខូចទ្រង់ទ្រាយនៃទម្រង់ដើម ហើយការបាត់បង់ផ្នែកហិរញ្ញវត្ថុដោយសារតែការរអាកខានអាជីវកម្មណាមួយដែលបណ្តាលមកពីការបាត់បង់ ឬការខូចខាតនោះ។ទោះបីជាយ៉ាងណាក៏ដោយ ការលើកលែង ការបាត់បង់នៃ ឬការខូចខាតចំពោះទិន្នន័យ ឬកម្មវិធី សូហ្វវែរនេះ ដែលជាលទ្ធផលផ្ទាល់នៃការខូចខាតជារូបវន្តចំពោះផ្នែកណាមួយនៃទ្រព្យសម្បត្តិរបស់បុគ្គលទទួលការធានារ៉ាប់រង ត្រូវបានធានារ៉ាប់រង។

ខ. ការបាត់បង់ ឬការខូចខាតដែលបណ្តាលមកពីការថយចុះប្រសិទ្ធភាពនៃមុខងារ ភាពអាចរកបាន ទំហំនៃការប្រើប្រាស់ ឬលទ្ធភាពប្រើប្រាស់ទិន្នន័យ កម្មវិធីកុំព្យូទ័រ ហើយការបាត់បង់ហិរញ្ញវត្ថុដោយសារតែការអាកខានអាជីវកម្មណាមួយ ដែលបណ្តាលមកពីការបាត់បង់ ឬការខូចខាតនោះ។

(Munich Re)

នៅក្នុងសកម្មភាព បណ្តឹង ឬដំណើរការក្តីណាមួយដែលក្រុមហ៊ុនធានារ៉ាប់រងចោទប្រកាន់ថា ដោយហេតុផលបទបញ្ញត្តិនៃការលើកលែង (ក) ការបាត់បង់ ការបំផ្លាញ ការបំផ្លាញ ការខូចខាត ឬការទទួលខុសត្រូវណាមួយខាងលើមិនត្រូវបានគ្របដណ្តប់ដោយការធានារ៉ាប់រងនេះទេ នោះការផ្តល់ភស្តុតាងថា ការបាត់បង់ ការបំផ្លាញ ការខូចខាត ឬការទទួលខុសត្រូវបែបនេះស្ថិតនៅក្រោមការធានារ៉ាប់រង ត្រូវក្លាយជាបន្ទុករបស់បុគ្គលទទួលការធានារ៉ាប់រង។

## រយៈពេលធានារ៉ាប់រង

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងត្រូវចាប់ផ្តើម ទោះបីជាវាផ្ទុយទៅនឹងកាលបរិច្ឆេទដែលចែងនៅក្នុងគម្រោងការងារនេះក៏ដោយ នៅពេលដែលចាប់ផ្តើមការងារ ឬក្រោយពេលដកការងារនេះចេញពីគម្រោងការងារនៅទីកន្លែងណាមួយក៏ដោយ។ ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រងផុតសុពលភាពចំពោះផ្នែកការងារចុះកិច្ចសន្យាដែលបុគ្គលទទួលការធានារ៉ាប់រងបានកាន់កាប់ ឬដាក់ឲ្យ ដំណើរការ។នៅពេលចុងក្រោយបំផុត ការធានារ៉ាប់រងត្រូវផុតសុពលភាពតាមកាលបរិច្ឆេទ ដែលមានចែងនៅក្នុងគម្រោងការងារ។ ការពន្យាពេលវេលាធានារ៉ាប់រងណាមួយត្រូវ មានការព្រមព្រៀងជាមុនជាលាយលក្ខណ៍អក្សរពីសំណាក់ក្រុមហ៊ុនធានារ៉ាប់រង។

## លក្ខខណ្ឌទូទៅ

១. ឧបសម្ព័ន្ធ និងការអនុវត្តតាមលក្ខខណ្ឌកំណត់នៃកិច្ចសន្យាធានារ៉ាប់រងនេះ ដរាបណាវាទាក់ទងទៅនឹងអ្វីដែលត្រូវធ្វើ ឬប្រតិបត្តិតាមដោយបុគ្គលទទួលការធានារ៉ាប់រង និងការពិតនៃសេចក្តីបញ្ជាក់ និងចម្លើយនៅក្នុងកម្រងសំនួរ និងសេចក្តីស្នើសុំដែលធ្វើឡើងដោយបុគ្គលទទួលការធានារ៉ាប់រង គឺជាលក្ខខណ្ឌដែលនាំឲ្យ មានការទទួលខុសត្រូវនៃបុគ្គលធានារ៉ាប់រង។

២. គម្រោងការងារ និងផ្នែកនានា ត្រូវចាត់ទុកថាត្រូវបានដាក់បញ្ចូល និងបង្កើតបានជាផ្នែកនៃកិច្ចសន្យាធានារ៉ាប់រងនេះហើយ ពាក្យ "កិច្ចសន្យាធានារ៉ាប់រងនេះ" ទោះបីជាត្រូវបានប្រើប្រាស់នៅចំនុចណាក៏ដោយក្នុងកិច្ចសន្យានេះ ត្រូវអានដោយបូកបញ្ចូលឧបសម្ព័ន្ធ និងផ្នែកផ្សេងៗ។ ពាក្យពេចន៍ ឬឃ្លាណាមួយដែលអត្ថន័យរបស់វាត្រូវបានភ្ជាប់នៅក្នុងផ្នែកណាមួយនៃកិច្ចសន្យាធានារ៉ាប់រងនេះ ឬក្នុងឧបសម្ព័ន្ធ ឬ ផ្នែកនានាត្រូវមានន័យថាបែបនេះទោះបីជានៅចំណុចណាក៏ដោយ។

៣. បុគ្គលទទួលការធានារ៉ាប់រងត្រូវមានវិធានការប្រុងប្រយ័ត្នសមហេតុផលដោយខ្លួន និងគោរពទៅតាម អនុសាសន៍សមហេតុផលរបស់ក្រុមហ៊ុនធានារ៉ាប់រងដើម្បីបង្ការការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវ ដោយមានលក្ខខណ្ឌតម្រូវស្របច្បាប់ និងអនុសាសន៍របស់អ្នកផលិត។

៤. ក) នៅពេលវេលាដ៏សមរម្យណាមួយ តំណាងក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិធ្វើការពិនិត្យពិច័យ និងត្រួតពិនិត្យហានិភ័យ ហើយបុគ្គលទទួលការធានារ៉ាប់រងត្រូវផ្តល់ជូនតំណាងបុគ្គលធានារ៉ាប់រងត្រូវជូនតំណាងបុគ្គលធានារ៉ាប់រងនូវព័ត៌មានលំអិត និងសំខាន់ៗនានាសម្រាប់ធ្វើការវាយតំលៃហានិភ័យ។

ខ) បុគ្គលទទួលការធានារ៉ាប់រងត្រូវជូនដំណឹងជាបន្ទាន់ដល់ក្រុមហ៊ុនធានារ៉ាប់រងតាមទូរលេខ និងលាយលក្ខណ៍អក្សរអំពីអ្វីដែលផ្លាស់ប្តូរនៅក្នុងហានិភ័យ និងមូលហេតុដោយត្រូវរ៉ាប់រងចំណាយផ្ទាល់ខ្លួន ចំពោះបម្រាមបន្ថែមដែលត្រូវអនុវត្តតាមកាលៈទេសៈតម្រូវ ហើយវិសាលភាពគ្របដណ្តប់ និង/ឬបុព្វលាភធានារ៉ាប់រងត្រូវធ្វើការកែសម្រួលតាមនោះប្រសិនបើចាំបាច់។

បុគ្គលទទួលការធានារ៉ាប់រងមិនត្រូវ ឬមិនអនុញ្ញាតឲ្យកែប្រែវត្ថុណាមួយ ដែលធ្វើឲ្យហានិភ័យកើនឡើងឡើយដរាបណាគ្មានការបញ្ជាក់ពីការបន្តការធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងជាលាយលក្ខណ៍អក្សរនោះទេ។

៥. នៅក្នុងករណីនៃហេតុការណ៍ណាមួយ ដែលអាចអោយមានការទាមទារសំណងទូទាត់ តាមកិច្ចសន្យាធានារ៉ាប់រងនេះ បុគ្គលទទួលការធានារ៉ាប់រងត្រូវៈ

ក) ជូនដំណឹងជាបន្ទាន់ដល់ក្រុមហ៊ុនធានារ៉ាប់រងតាមទូរស័ព្ទ ឬទូរលេខ ក៏ដូចជាតាមលិខិតជាលាយលក្ខណ៍អក្សរ ដោយផ្តល់ជូននូវការចង្អុលបង្ហាញពីលក្ខណៈនិងវិសាលភាពនៃការបាត់បង់ និងការខូចខាត។

ខ) អនុវត្តរាល់ជំហានដើម្បីកាត់បន្ថយវិសាលភាពនៃការបាត់បង់ និងការខូចខាត។

គ) រក្សាទុកនូវផ្នែកដែលខូចខាត និងធ្វើអោយវាស្ថិតក្នុងភាពអាចពិនិត្យបានដោយតំណាង ឬអ្នកអង្កេតការរបស់ក្រុមហ៊ុនធានារ៉ាប់រង។

ឃ) ផ្តល់នូវព័ត៌មាន និងឯកសារភស្តុតាងនានា នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងអាចនឹងទាមទារ។

ង) ផ្តល់ដំណឹងជូនអាជ្ញាធរនគរបាលក្នុងករណីដែលមានការបាត់បង់ ឬខូចខាតដោយសារចោរកម្ម ឬការលបចូលលួច។

ក្នុងករណីណាក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងមិនទទួលខុសត្រូវចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវណាមួយដែលគ្មានការជូនដំណឹងក្នុងរយៈពេល១៤ថ្ងៃក្រោយពេលកើតហេតុឡើយ។

នៅពេលដែលការជូនដំណឹង ត្រូវបានផ្តល់ជូនទៅក្រុមហ៊ុនធានារ៉ាប់រងតាមលក្ខខណ្ឌនេះ បុគ្គលទទួលការធានារ៉ាប់រងអាចធ្វើការជួសជុល ឬផ្លាស់ប្តូរចំពោះការខូចខាតបន្តិចបន្តួចណាមួយ ក្នុងករណីណាក៏ដោយ តំណាងក្រុមហ៊ុនធានារ៉ាប់រងត្រូវមានឱកាសពិនិត្យលើការបាត់បង់ ឬខូចខាតមុនពេលដែលមានការជួសជុល ឬកែប្រែណាមួយ។ ប្រសិនបើតំណាងរបស់ក្រុមហ៊ុនធានារ៉ាប់រងមិនធ្វើការពិនិត្យក្នុងរយៈពេលមួយ ដែលអាចចាត់ទុកថាសមល្មម តាមកាលៈទេសៈនោះទេបុគ្គលទទួលការធានារ៉ាប់រងមានសិទ្ធិធ្វើការជួសជុល ឬផ្លាស់ប្តូរបាន។

ការទទួលខុសត្រូវរបស់ក្រុមហ៊ុនធានារ៉ាប់រង ដោយអនុលោមតាមកិច្ចសន្យាធានារ៉ាប់រងនេះ ចំពោះវត្ថុណាដែលរងការខូចខាតនោះនឹងត្រូវបញ្ចប់ ប្រសិនបើវត្ថុនោះមិនត្រូវបានជួសជុលអោយបានត្រឹមត្រូវ ដោយគ្មានការពន្យាពេល។

៦. ដោយប្រើសោហ៊ុយរបស់ក្រុមហ៊ុនធានារ៉ាប់រង បុគ្គលទទួលការធានារ៉ាប់រងត្រូវធ្វើ និងយល់ព្រមក្នុងការធ្វើ និងអនុញ្ញាតឲ្យធ្វើនូវសកម្មភាព និងការងារនេះតាមការចាំបាច់ ឬការតម្រូវដោយក្រុមហ៊ុនធានារ៉ាប់រងជាប្រយោជន៍នៃសិទ្ធិ ឬដំណោះស្រាយណាមួយ ឬនៃការសម្រួល ឬសំណងទូទាត់ពីភាគី (ក្រៅពីបុគ្គលទទួលការធានារ៉ាប់រងក្រោមកិច្ចសន្យាធានារ៉ាប់រងនេះ) ដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវ ឬក្លាយជាមានសិទ្ធិ ឬកាតព្វកិច្ចបង់ថ្លៃជូន ឬធ្វើការប៉ះប៉ូវការបាត់បង់ ឬខូចខាតតាមកិច្ចសន្យាកិច្ចសន្យាធានារ៉ាប់រងនេះ ទោះជាសកម្មភាព ឬបញ្ហាបែបនេះមានលក្ខណៈ ឬក្លាយជាចាំបាច់ ឬត្រូវបានទាមទារមុន ឬក្រោយការសងសំណងដោយក្រុមហ៊ុនធានារ៉ាប់រងអោយទៅបុគ្គលទទួលការធានារ៉ាប់រងក៏ដោយ។

៧. ប្រសិនបើចំនួនទឹកប្រាក់ដែលត្រូវបង់មានភាពខុសគ្នា តាមកិច្ចសន្យាធានារ៉ាប់រងនេះ (ម្យ៉ាងទៀតសំណងត្រូវបានទទួលយក) ភាពខុសគ្នាបែបនេះត្រូវអាស្រ័យទៅតាមសេចក្ដីសំរេចរបស់អាជ្ញាកណ្ដាលដែលនឹងតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីដោយភាពខុសគ្នា ឬប្រសិនបើពួកគេមិនយល់ព្រមតាមអាជ្ញាកណ្ដាលតែម្នាក់ទេនោះ ដើម្បីមានសេចក្ដីសំរេចពីអាជ្ញាកណ្ដាលពីររូប ដែលម្នាក់ត្រូវបានតែងតាំងជាលាយលក្ខណ៍អក្សរដោយភាគីនីមួយៗ ក្នុងរយៈពេលមួយខែក្រោយពីមានការទាមទារជាលាយលក្ខណ៍អក្សរឲ្យ ធ្វើដូចច្នេះដោយភាគីណាមួយ ឬក្នុងករណីដែលអាជ្ញាកណ្ដាលមិនយល់ព្រម អាជ្ញាកណ្ដាលម្នាក់ទៀតនឹងត្រូវតែងតាំងជាលាយលក្ខណ៍អក្សរដោយអាជ្ញាកណ្ដាលពីររូបនោះមុនពេលចូលជាសំអាង។ អាជ្ញាកណ្ដាលនេះត្រូវអង្គុយជាមួយកណ្ដាលពីររូបនោះ និងធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ពួកគេ។ សេចក្ដីសម្រេចរបស់មជ្ឈត្តកម្មគឺជាលក្ខខណ្ឌមុនពេលផ្ដល់សិទ្ធិឲ្យ ធ្វើសកម្មភាពប្រឆាំងនឹងក្រុមហ៊ុនធានារ៉ាប់រង។

៨. ប្រសិនបើការទាមទារសំណងមានលក្ខណៈក្លែងបន្លំ ឬប្រសិនបើសេចក្ដីប្រកាសក្លែងក្លាយត្រូវបានគេធ្វើឡើង ឬប្រើប្រាស់ក្នុងការគាំទ្រ ឬប្រសិនបើមធ្យោបាយ ឬឧបករណ៍ក្លែងបន្លំត្រូវបានយកមកប្រើប្រាស់ដោយបុគ្គលទទួលការធានារ៉ាប់រង ឬនរណាម្នាក់ធ្វើជាតំណាងឲ្យគាត់ ទទួលបានផលប្រយោជន៍តាមកិច្ចសន្យាធានារ៉ាប់រងនេះ ឬប្រសិនបើការទាមទារសំណងត្រូវបានច្រានចោល ហើយគ្មានសកម្មភាព ឬបណ្ដឹងអ្វីចាប់ផ្ដើមក្នុងរយៈពេលបីខែក្រោយការច្រានចោលនេះ ឬក្នុងករណីអាជ្ញាកណ្ដាលកើតឡើងដូចបានរៀបរាប់រួចមកហើយក្នុងរយៈពេលបីខែ ក្រោយពីអាជ្ញាកណ្ដាលមួយរូប ឬច្រើនរូប ឬមជ្ឈត្តករបានចេញសេចក្ដីសម្រេចរបស់ពួកគេ រាល់ផលប្រយោជន៍ក្រោមកិច្ចសន្យាធានារ៉ាប់រងនេះនឹងត្រូវរឹបអូសយក។

៩. ប្រសិនបើនៅពេលដែលមានការទាមទារសំណងណាមួយកើតឡើង តាមកិច្ចសន្យាធានារ៉ាប់រងនេះ មានការធានារ៉ាប់រងផ្សេងទៀតដែលគ្របដណ្ដប់លើការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវដូចគ្នា បុគ្គលធានារ៉ាប់រងមិនទទួលខុសត្រូវក្នុងការធ្វើសំណង ឬរួមវិភាគទានច្រើនជាងសមមាត្រនៃការទាមទារសំណងចំពោះការបាត់បង់ ការខូចខាត ឬការទទួលខុសត្រូវឡើយ។

១០. ការធានារ៉ាប់រងនេះអាចត្រូវបញ្ចប់ នៅពេលណាមួយតាមសំណើររបស់បុគ្គលដែលត្រូវបានធានារ៉ាប់រងដោយជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ក្នុងករណីនេះក្រុមហ៊ុននឹងបង់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រង នូវបុព្វលាភធានារ៉ាប់រងចំនួន ៩០% សម្រាប់រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះដោយក្នុងលក្ខខណ្ឌថាពុំមានបណ្ដឹងទាមទារសំណងណាមួយកើតឡើង ក្នុងកំឡុងពេលនៃការធានារ៉ាប់រងនេះទេ។កិច្ចសន្យាធានារ៉ាប់រងនេះក៏អាចត្រូវបានបញ្ចប់ផងដែរតាមជម្រើសរបស់ក្រុមហ៊ុន ដោយធ្វើការជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១០ថ្ងៃ ជាមុនតាមរយៈលិខិតអនុសិដ្ឋទៅកាន់អាសយដ្ឋានដែលគេស្គាល់ចុងក្រោយ របស់បុគ្គលដែលត្រូវបានធានារ៉ាប់រង ក្នុងរកណីនេះក្រុមហ៊ុននឹងបង់ជូនបុគ្គលដែលត្រូវបានធានារ៉ាប់រងនូវអត្រាបុព្វលាភធានារ៉ាប់រងសម្រាប់ រយៈពេលដែលនៅមានសុពលភាព គិតចាប់ពីថ្ងៃមោឃភាពនៃកិច្ចសន្យាធានារ៉ាប់រងនេះ។

**លក្ខខណ្ឌធានាចំពោះបុព្វលាភធានារ៉ាប់រង**

នេះគឺជាលក្ខខណ្ឌមូលដ្ឋាន និងពិសេសបំផុតនៃកិច្ចសន្យាធានារ៉ាប់រងនេះ ដែលបុព្វធានារ៉ាប់រងដែលត្រូវបង់នឹងទទួលដោយក្រុមហ៊ុនក្នុងរយៈពេល សាមសិប(៣០)ថ្ងៃ ចាប់ពីកាលបរិច្ឆេទចាប់ផ្ដើមកិច្ចសន្យាធានារ៉ាប់រងនេះ/បង្កាន់ដៃ/លិខិតបន្តការធានារ៉ាប់រងថ្មី។ ប្រសិនបើលក្ខខណ្ឌនេះមិនត្រូវបានគោរពតាម នោះកិច្ចសន្យានេះនឹងត្រូវលុបចោលដោយស្វ័យប្រវត្តិ ហើយក្រុមហ៊ុនមានសិទ្ធិទទួលបានបុព្វលាភ ធានារ៉ាប់រងតាមសមាមាត្រសំរាប់រយៈពេលដែលក្រុមហ៊ុនស្ថិតក្នុងហានិភ័យ។

ប្រសិនបើបុព្វលាភធានារ៉ាប់រងដែលត្រូវបង់ស្របតាមការធានានេះ ត្រូវបានទទួលដោយភ្នាក់ងារមានការអនុញ្ញាតរបស់ក្រុមហ៊ុន ប្រាក់នេះត្រូវចាត់ទុកថាបានទទួលដោយក្រុមហ៊ុន សម្រាប់គោលបំណងនៃការធានានេះ ហើយកាតព្វកិច្ចក្នុងការកំណត់ថាបុព្វលាភធានារ៉ាប់រងដែលត្រូវបានទទួលដោយបុគ្គលម្នាក់ រួមទាំងភ្នាក់ងារធានារ៉ាប់រងដែលមិនត្រូវបានអនុញ្ញាតឲ្យទទួលបុព្វលាភ ធានារ៉ាប់រងនោះត្រូវធ្លាក់លើក្រុមហ៊ុន។

រាល់លក្ខខណ្ឌ និង ខ ចែងទាំងអស់ត្រូវផ្អែកលើកិច្ចសន្យាធានារ៉ាប់រងនេះ។

**ខចែងស្ដីអំពីការដាក់កំហិតទណ្ឌកម្ម និងករណីលើកលែង (LMA3100)**

គ្មានក្រុមហ៊ុនធានារ៉ាប់រងណាមួយ អាចផ្ដល់ការធានារ៉ាប់រង និងទទួលខុសត្រូវចំពោះការផ្ដល់ប្រាក់សំណង ណាមួយឬផ្ដល់អត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះ បានឡើយដែលការផ្ដល់ប្រាក់សំណង ឬអត្ថប្រយោជន៍ណាមួយដែលស្ថិតនៅក្នុងដែនកំណត់នៃបុរេលក្ខខណ្ឌនៃការធានារ៉ាប់រងនោះ បានឡើយដែលការផ្ដល់ប្រាក់សំណង ឬអត្ថប្រយោជន៍ទាំងនោះធ្វើឲ្យ ក្រុមហ៊ុនធានារ៉ាប់រង ប្រឈមមុខ នឹងការដាក់ទណ្ឌកម្មណាមួយការហាមឃាត់ ឬការដាក់កម្រិតដែលស្ថិតនៅក្រោមសេចក្ដីសម្រេចរបស់ អង្គការសហប្រជាជាតិ ឬការដាក់ទណ្ឌកម្មផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ច្បាប់ ឬនិយតកម្មរបស់សហគមន៍អឺរ៉ុប ចក្រភពអង់គ្លេស ឬសហរដ្ឋអាមេរិក។

<u>**ផ្នែកទី១-ការខូចខាតសម្ភារៈ**</u>

ក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមជាមួយនឹងបុគ្គលទទួលការធានារ៉ាប់រងថា ប្រសិនបើពេលណាមួយក្នុងកំឡុងរយៈពេលនៃការធានារ៉ាប់រងសម្ភារៈ ឬផ្នែកណាមួយនៃសម្ភារៈនោះចុះក្នុងឧបសម្ព័ន្ធទទួលរងការបាត់បង់ ឬខូចខាតដោយចៃដន្យដែលបណ្ដាលមកពីមូលហេតុណាមួយ ក្រៅពីមូលហេតុទាំងឡាយណាដែលបានលើកលែងយ៉ាងជាក់លាក់ទាំងនោះ ក្នុងលក្ខណៈនៃការជួសជុល ឬផ្លាស់ប្ដូរជាចាំបាច់ ក្រុមហ៊ុនធានារ៉ាប់រងនឹងសងទូទាត់ទៅឲ្យបុគ្គលទទួលការធានារ៉ាប់រងចំពោះការបាត់បង់ ឬខូចខាតនេះ ដែលតទៅនឹងផ្ដល់ជូនជាសាច់ប្រាក់ ការផ្លាស់ប្ដូរ ឬជួសជុល (តាមការជ្រើសរើសរបស់ពួកគេ) រហូតដល់ចំនួនដែលមិនលើសពីអ្វី ដែលមានចែងចៅក្នុងឧបសម្ព័ន្ធ នៃចំនួនទឹកប្រាក់សរុបដែលផ្ទុយ ពីនេះ និងដែលមិនលើសពីហេតុការណ៍ណាមួយនូវដែនកំណត់នៃការសងទូទាត់ណាដែលអាចធ្វើទៅបាន ហើយដែលមិន លើសពីចំនួននៃការចំណាយសរុបនៅក្នុងឧបសម្ព័ន្ធដែលត្រូវធានារ៉ាប់រងដូចខាងក្រោម។

ក្រុមហ៊ុនធានារ៉ាប់រងក៏ នឹងចេញសងជូនដល់បុគ្គលទទួលការធានារ៉ាប់រងផងដែរ នូវតម្លៃបោសសំអាតកាកសំណល់ក្នុងហេតុការណ៍ណាមួយដែលនាំឲ្យមានការទាមទារសំណងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ដែលបានបញ្ជាក់ពីចំនួនដាច់ដោយឡែកដូចដែលបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ។

**ការលើកលែងពិសេសចំពោះផ្នែកទី១**

ទោះបីយ៉ាងណាក៏ដោយ ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលខុសត្រូវចំពោះ

- ក) កម្រិតមិនធ្វើសំណងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ដែលត្រូវអនុវត្តតាមដោយអ្នកទទួលការធានារ៉ាប់រងនៅក្នុងហេតុការណ៍ណាមួយដែលកើតឡើង។
- ខ) ការបាត់បង់មិនចំពោះនៃប្រភេទ ឬការបរិយាយណាមួយក៏ដោយ ដោយរាប់បញ្ចូលទាំងការផាកពិន័យ ការខាតបង់ដោយសារតែការពន្យាពេល ការខ្វះចន្លោះនៃការអនុវត្ត ការបាត់បង់កិច្ចសន្យា។
- គ) ការបាត់បង់ ឬខូចខាតដោយសារកំហុសនៃការរចនា។
- ឃ) តម្លៃនៃការផ្លាស់ប្ដូរ ការជួសជុល ឬការកែប្រែសម្ភារៈ និង/ឬទឹកដៃដែលមានឥតខ្ចោះ ប៉ុន្តែការលើកលែងនេះត្រូវកំណត់ចំពោះសម្ភារៈដែលទើបតែរងការខូចខាតភ្លាមៗ និងមិនត្រូវបានគេចាត់ទុកថាលើកលែងការបាត់បង់នៃ ឬការខូចខាតនៃវត្ថុដែលត្រូវបានធ្វើឡើងដោយត្រឹមត្រូវ ដែលបណ្ដាលមកពីគ្រោះថ្នាក់ដោយសារភាពមានឥតខ្ចោះនៃសម្ភារៈ និង/ឬទឹកដៃនោះ។

ង)	ការសឹករិចរិល ការរហែក ការដាច់ ច្រេះចាប់ ការខូច ដោយសារកង្វះខាតនៃការប្រើប្រាស់ និងស្ថានភាពបរិយាកាសធម្មតា។

ច)	ការខូចផ្នែកមេកានិក និង/ឬអគ្គិសនី ឬការរុះរើសំណង់ សម្ភារៈ និងគ្រឿងចក្រសំរាប់សាងសង់។

ឆ)	ការបាត់បង់ ឬខូចខាតយានយន្តដែលមានអាជ្ញាប័ណ្ណសម្រាប់ ការប្រើប្រាស់ទូទៅ ឬកប៉ាល់ទឹក ឬយន្តហោះ។

ជ)	ការបាត់បង់ ការខូចខាតឯកសារ គំនូរព្រាង គណនី វិក្កយប័ត្រ រូបិយប័ណ្ណ ត្រា ប័ណ្ណកម្មសិទ្ធិ ភស្តុតាងនៃបំណុល ប័ណ្ណមូលប័ត្រ មូលប្បទានប័ត្រ។

ឈ)	ការបាត់បង់ដែលត្រូវបានរកឃើញតែនៅពេលធ្វើបញ្ជីសារពើភ័ណ្ឌ។

**បទប្បញ្ញត្តិដែលអនុវត្តចំពោះផ្នែកទី១**

**១.	ចំនួនទឹកប្រាក់ដែលត្រូវធានារ៉ាប់រង**

វាជាលក្ខខណ្ឌតម្រូវនៃការធានារ៉ាប់រងនេះដែលថា ចំនួនទឹកប្រាក់ដែលត្រូវធានានៅក្នុងគម្រោងការងារ មិនត្រូវមានចំនួនតិចជាង:

***សម្រាប់ចំនុចទី១ :***

តម្លៃពេញនៃការងារដែលជាប់កិច្ចសន្យា នៅពេលដែលកិច្ចការសាងសង់បានបញ្ចប់ ដោយរួមបញ្ចូលទាំងសម្ភារៈទាំងអស់ ប្រាក់ឈ្នួល ថ្លៃដឹកជញ្ជូន ភាសុី ពន្ធគយ ពេលវេលាកំណត់ និងសម្ភារៈ ឬទំនិញដែលផ្តល់អោយដោយគូភាគីទទួលខុសត្រូវ។

***សម្រាប់ចំនុចទី២ និងទី៣ :***

តម្លៃនៃការផ្លាស់ប្តូររបស់ក្រុមហ៊ុនសំណង់ សម្ភារៈ និងគ្រឿងចក្រសំណង់ ដែលត្រូវមានន័យថា ជាតម្លៃនៃការផ្លាស់ប្តូរទំនិញដែលត្រូវបានធានារ៉ាប់រង ដោយទំនិញថ្មីដែលមានប្រភេទ និងសមត្ថភាពដូចគ្នា។

ចំណែកឯបុគ្គលទទួលរងការធានារ៉ាប់រងត្រូវទទួលបន្ទុកបង្កើន និងបន្ថយបរិមាណនៃការធានារ៉ាប់រងនៅក្នុងហេតុការណ៍ដែលសម្ភារៈណាមួយមានការប្រែប្រួលចំពោះថ្លៃឈ្នួល និងតម្លៃរបស់វា ដោយសារតែការកើនឡើង និងការថយចុះបែបនេះចូលជាធរមានតែក្រោយពេលទំនិញដូចគ្នានេះ ត្រូវបានកត់ត្រាទុកត្រានៅក្នុងគម្រោងការងារ នៅក្នុងកិច្ចសន្យាធានារ៉ាប់រង ដោយក្រុមហ៊ុនធានារ៉ាប់រង។

ប្រសិនបើក្នុងករណីបាត់បង់ ឬខូចខាត វាត្រូវបានគេរកឃើញថា ចំនួនទឹកប្រាក់ដែលត្រូវធានាតិចជាងចំនួនទឹកប្រាក់ដែលទាមទារឲ្យធានារ៉ាប់រង ដូច្នេះចំនួនទឹកប្រាក់ដែលអាចគ្របដណ្តប់ដោយបុគ្គលទទួលការធានារ៉ាប់រងតាមកិច្ចសន្យាធានារ៉ាប់រងនេះ ត្រូវកាត់បន្ថយតាមសមមាត្រនៃចំនួនទឹកប្រាក់សរុប ដែលបុគ្គលទទួលការធានារ៉ាប់រងត្រូវបានទៅតាមចំនួនដែលទាមទារឲ្យធានារ៉ាប់រង។

រាល់វត្ថុ និងតម្លៃនៃទំនិញនឹងត្រូវស្ថិតនៅក្នុងលក្ខខណ្ឌនេះដាច់ដោយឡែកពីគ្នា។

**២.	មូលដ្ឋាននៃដំណោះស្រាយចំពោះការបាត់បង់**

ក្នុងករណីដែលមានការបាត់បង់ ឬខូចខាត មូលដ្ឋាននៃដំណោះស្រាយដែលមានចែងនៅក្នុងកិច្ចសន្យាធានារ៉ាប់រងនេះគឺ

ក)	ក្នុងករណីនៃការខូចខាតដែលអាចជួសជុលបាន - ដំណោះស្រាយជាមូលដ្ឋានគឺតម្លៃនៃការជួសជុលដែលចាំបាច់ដើម្បីស្តារទំនិញឲ្យ ត្រឡប់ ទៅរកស្ថានភាពរបស់វា ភ្លាមមុនពេលដែលទំនិញនោះខូចខាតធ្ងន់ធ្ងរ ឬ

ខ)	ក្នុងករណីដែលមានការខូចខាតទាំងស្រុង - ដំណោះស្រាយជាមូលដ្ឋានគឺតម្លៃទំនិញជាក់ស្តែងភ្លាមៗមុនពេលហេតុការណ៍នៃការបាត់បង់ដោយដកតម្លៃស្រង់ដើមចេញ។

ទោះបីយ៉ាងណាក៏ដោយ លុះត្រាតែតម្លៃសំណងដែលត្រូវទាមទារចាំបាច់ត្រូវរ៉ាប់រងដោយបុគ្គលទទួលការធានារ៉ាប់រង ហើយលុះត្រាតែតម្លៃនោះត្រូវបានរាប់បញ្ចូលទៅក្នុងតម្លៃដែលត្រូវធានារ៉ាប់រង ហើយលុះត្រាតែបញ្ញត្តិ និងលក្ខខណ្ឌទាំងនោះត្រូវបានគេចងក្រងបញ្ចូលគ្នា។

ក្រុមហ៊ុនធានារ៉ាប់រងបង់ថ្លៃសំណងទូទាត់តែនៅពេលដែលមានវិក្កយប័ត្រសំខាន់ៗ និងឯកសារបញ្ជាក់ថាទំនិញនោះត្រូវខូច ឬមានការផ្លាស់ប្តូរតាមករណីដែលអាចកើតមាន។

រាល់ការខូចខាតដែលអាចជួសជុលបានធ្វើការជួសជុល ប៉ុន្តែ ប្រសិនបើតម្លៃជួសជុលការខូចខាតណាមួយដែលស្មើ ឬលើសពីតម្លៃនៃ

ទំនិញ មុនពេលមានការខូចខាតកើតឡើង ភ្លាមៗ នោះ ត្រូវរកដំណោះស្រាយដោយផ្អែកលើមូលដ្ឋានដែលមានចែងនៅក្នុង (ខ) ខាងលើ។
តម្លៃនៃការជួសជុលបណ្ដោះអាសន្ននឹងជាបន្ទុករបស់បុគ្គលធានារ៉ាប់រង ប្រសិនបើការជួសជុលបែបនេះស្រប ទៅតាមផ្នែកនៃការជួសជុលចុងក្រោយ ហើយមិនមានការបង្កើនចំណាយសរុបលើការជួសជុលនោះទេ។
តម្លៃនៃការផ្លាស់ប្តូរ ការបន្ថែម និង/ឬការធ្វើឲ្យប្រសើរឡើងណាមួយ មិនស្ថិតនៅក្រោមការគ្របដណ្តប់របស់កិច្ចសន្យាធានារ៉ាប់រងនេះឡើយ។

**វិសាលភាពបន្ថែមនៃការធានារ៉ាប់រង**

តម្លៃសេវាបន្ថែមនៃការងារម៉ោងបន្ថែម ការងារពេលយប់ ការងារធ្វើនៅថ្ងៃឈប់សម្រាក បុណ្យជាតិ ការដឹកជញ្ជូនរហ័សត្រូវគ្របដណ្តប់ដោយកិច្ចសន្យាធានារ៉ាប់រងនេះ លុះត្រាតែមានការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរជាមុន និងជាពិសេស។

## <u>ផ្នែកទី២~ការទទួលខុសត្រូវចំពោះភាគីតតីយជន</u>

ក្រុមហ៊ុនធានារ៉ាប់រងនឹងចេញសំណងដល់បុគ្គលទទួលការធានារ៉ាប់រងរហូតដល់ ប៉ុន្តែមិនឲ្យលើសពីចំនួនដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធ លើចំនួនទឹកប្រាក់សរុបដែលបុគ្គលទទួលការធានារ៉ាប់រងទទួលខុសត្រូវក្នុងការបង់ជូននៅពេលមានការខូចខាតកើតឡើងជាលទ្ធផលនៃ

ក) របួសដោយចៃដន្យលើរាងកាយ ឬជំងឺរបស់តតីយជន (ទោះបណ្តាលឲ្យស្លាប់ ឬមិនស្លាប់ក៏ដោយ)។

ខ) ការបាត់បង់ ឬខូចខាតដោយចៃដន្យលើទ្រព្យសម្បត្តិរបស់តតីយជន។
ការកើតមាននូវការជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងការសាងសង់ ឬការតម្លើងវត្ថុដែលត្រូវធានានៅក្នុងផ្នែកទី១ និង ដែលកើតឡើងនៅបរិវេណក្បែរៗការដ្ឋានក្នុងរយៈពេលនៃការធានារ៉ាប់រង។
ចំពោះការទាមទារសំណងជំងឺចិត្តដែលសំណងទូទាត់នេះនឹងត្រូវអនុវត្ត ក្រុមហ៊ុនធានារ៉ាប់រងនឹងទូទាត់សងបន្ថែមទៅកាន់បុគ្គលទទួលការធានារ៉ាប់រងចំពោះ

ក) រាល់ថ្លៃ និងការចំណាយលើបណ្តឹងដែលទាមទារដោយអ្នកទាមទារសំណងណាម្នាក់ពីបុគ្គលទទួលការធានារ៉ាប់រង និង

ខ) រាល់ថ្លៃ និងការចំណាយដែលត្រូវរ៉ាប់រងដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីបុគ្គលធានារ៉ាប់រង។
ក្នុងករណីការទទួលខុសត្រូវរបស់បុគ្គលធានារ៉ាប់រងនៅក្នុងផ្នែកនេះ មិនលើសពីដែនកំណត់នៃសំណងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ។

**ការលើកលែងពិសេសចំពោះផ្នែកទី២**

ក្រុមហ៊ុនធានារ៉ាប់រងនឹងមិនធានាសងបុគ្គលទទួលការធានារ៉ាប់រងឡើយ ទាក់ទិននឹង:

១. ចំនួនកម្រិតមិនធ្វើសំណងដែលមានចែងនៅក្នុងឧបសម្ព័ន្ធ ដែលត្រូវអនុវត្តដោយបុគ្គលទទួលការធានារ៉ាប់រង នៅក្នុងហេតុការណ៍ណាមួយ។

២. ការចំណាយដែលអាចកើតមានក្នុងការធ្វើ ឬប៉ះប៉ូវ ឬជួសជុល ឬជំនួសអ្វីដែលគ្របដណ្តប់ ឬអាចគ្របដណ្តប់ដោយផ្នែកទី១ នៃកិច្ចសន្យាធានារ៉ាប់រងនេះ។

៣. ការខូចខាតទ្រព្យសម្បត្តិ ឬដីធ្លី ឬអគារណាមួយដែលបណ្តាលមកពីរំញ័រ ឬដោយការរំកិលចេញ ឬការធ្វើឲ្យចុះខ្សោយនៃទម្រ ឬធ្វើឲ្យរបួស ឬខូចខាតដល់បុគ្គលណាម្នាក់ ឬទ្រព្យសម្បត្តិ ដែលបណ្តាលមកពីការធ្វើឲ្យខូចខាតដោយរបៀបនេះ(ជាពិសេសលុះត្រាតែមានការយល់ព្រមដោយមានការបញ្ជាក់ក្នុងបដិលេខ)។

៤. ការទទួលខុសត្រូវចំពោះលទ្ធផលនៃ

ក) របួសលើរាងកាយ ឬជំងឺរបស់បុគ្គលិក ឬអ្នកធ្វើការឲ្យអ្នកម៉ៅការសំណង់ ឬភាគីទទួលខុសត្រូវ ឬក្រុមហ៊ុន ណាមួយដែលជាប់ពាក់ព័ន្ធនឹងគម្រោងដែល ឬផ្នែករបស់វាត្រូវបានធានារ៉ាប់រងដោយផ្នែកទី១ ឬសមាជិកគ្រួសារ របស់ពួកគេ។

ខ)	ការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការថែរក្សារបស់អ្នកម៉ៅការ ភាគីទទួលខុសត្រូវ ឬក្រុមហ៊ុនណាមួយដែលជាប់ពាក់ព័ន្ធនឹងគម្រោងដែល ឬផ្នែករបស់វាត្រូវបានធានារ៉ាប់រងដោយផ្នែកទី១ បុគ្គលិក ឬអ្នកធ្វើការរបស់អ្នកទាំងនោះណាមួយ។

គ)	គ្រោះថ្នាក់ណាមួយដែលបង្កឡើងដោយយានយន្ត ដែលមានអាជ្ញាប័ណ្ណសម្រាប់ប្រើប្រាស់លើផ្លូវទូទៅ កប៉ាល់ទឹក ឬយន្តហោះ។

ឃ)	ការព្រមព្រៀងណាមួយដោយបុគ្គលទទួលការធានារ៉ាប់រងក្នុងការបង់ប្រាក់ក្នុងលក្ខណៈធានាសំណងទូទាត់ ឬបើមិនដូច្នោះទេការទទួលខុសត្រូវបែបនេះក៏អាចភ្ជាប់ផងដែរនៅពេលដែលគ្មានការព្រមព្រៀងបែបនេះ។

**លក្ខខណ្ឌពិសេសអនុវត្តចំពោះផ្នែកទី ២**

១.	មិនមានការអនុញ្ញាត ការផ្តល់ ការសន្យា ការបង់ប្រាក់ ឬការធានាំណងណាមួយត្រូវបានធ្វើឡើង ឬផ្តល់ឲ្យដោយ ឬក្នុងនាមបុគ្គលទទួលការធានារ៉ាប់រងដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សររបស់ ក្រុមហ៊ុនធានារ៉ាប់រងដែលត្រូវមានសិទ្ធិឡើយ ប្រសិនបើពួកគេមានបំណងធ្វើដូច្នេះដើម្បីកាន់កាប់ និងធ្វើក្នុងនាមបុគ្គលទទួលការធានារ៉ាប់រង ការការពារ ឬដំណោះស្រាយនូវការប្តឹងទាមទារណាមួយ ឬដើម្បីសម្រេចឲ្យបានផលប្រយោជន៍ផ្ទាល់របស់ពួកគេក្នុងនាមបុគ្គលទទួលការធានារ៉ាប់រងនូវបណ្តឹងទាមទារការធានាសំណង ឬសំណងលើការខូចខាត បើមិនដូច្នោះទេត្រូវមានឆន្ទានុសិទ្ធិពេញលេញក្នុងការប្រតិបត្តិដំណើរការណាមួយ ឬនៅក្នុងការដោះស្រាយចំពោះការប្តឹងទាមទារណាមួយ ហើយបុគ្គលទទួលការធានារ៉ាប់រងត្រូវផ្តល់ជូននូវព័ត៌មាន និងជំនួយបែបនេះតាមដែលក្រុមហ៊ុនធានារ៉ាប់រងអាចត្រូវការ។

២.	ក្រុមហ៊ុនធានារ៉ាប់រងអាចសងទៅបុគ្គលទទួលការធានារ៉ាប់រង ចំពោះគ្រោះថ្នាក់ទាំងឡាយ ដែលពាក់ព័ន្ធនូវសំណងទូទាត់ចំពោះគ្រោះថ្នាក់ណាមួយ (ប៉ុន្តែកាត់រំលោះចេញនូវទឹកប្រាក់មួយចំនួនចំពោះករណីបែបនេះ ឬទឹកប្រាក់ដែលបានសងជាសំណងជំងឺចិត្តចំពោះករណីនេះរួចហើយ) ឬចំនួនទឹកប្រាក់ដែលតិចជាងនេះ សម្រាប់បណ្តឹងទាមទារដែលកើតចេញពីគ្រោះថ្នាក់ដែលអាចដោះស្រាយបាន រីឯក្រុមហ៊ុនធានារ៉ាប់រងនឹងមិនទទួលខុសត្រូវទៀតឡើយចំពោះគ្រោះថ្នាក់បែបនេះនៅក្នុងផ្នែកនេះ។

៣.	ក្រុមហ៊ុនមិនទទួលខុសត្រូវឡើយក្នុងការសង:

ក)	សំណងលើការខូចខាតទាក់ទិននឹងសាលក្រមដែលមិនបានផ្តល់ជូន ឬបានទទួលពីតុលាការនៃយុត្តាធិការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ខ)	រាល់ថ្លៃ និងការចំណាយលើបណ្តឹងដែលទាមទារដោយអ្នកទាមទារសំណងណាម្នាក់ ពីបុគ្គលទទួលការធានារ៉ាប់រងដែលមិនបានកើតឡើង និងទាមទារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។